ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១២ លេខ ១៤ សប្តាហ៍ទី ៣ ថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១២

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃជាវ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាវជាមុន)

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

p

មាតិកា

I. ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១៦.០២.២០១២ - ព្រះរាជក្រឹត្យ នស/រកត/០២១២/០៧៩ ស្ដីពី ការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រង និង អភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ១២៥៧

១៦.០២.២០១២ - ព្រះរាជក្រឹត្យ នស/រកត/០២១២/០៨០ ស្ដីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតួបការ ចំពោះ លោកជំទាវ អ៊ិត ម៉ាលី ១២៦២

១៦.០២.២០១២ - ព្រះរាជក្រឹត្យ នស/រកត/០២១២/០៨១ ស្ដីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឥស្សរជនជប៉ុន ចំនួន ០៣ រូប ១២៦៣

១៦.០២.២០១២ - ព្រះរាជក្រឹត្យ នស/រកត/០២១២/០៨២ ស្ដីពី ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ឯក នៃកងយោធពលខេមរភូមិន្ទ ជូនឯកឧត្តម ឧត្តមសេនីយ៍ទោ ម៉ិន គី ១២៦៤

១៦.០២.២០១២ - ព្រះរាជក្រឹត្យ នស/រកត/០២១២/០៨៣ ស្ដីពី ការតែងតាំង លោក អ៊ិត ធី ជាឧកញ៉ា ១២៦៥

១៦.០២.២០១២ - ព្រះរាជក្រឹត្យ នស/រកត/០២១២/០៨៤ ស្ដីពី ការដំឡើងឋានៈជូនជំនួយការសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចំនួន ០២ រូប មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ដោយពុំទទួលប្រាក់បៀវត្ស ១២៦៦

១៦.០២.២០១២ - ព្រះរាជក្រឹត្យ នស/រកត/០២១២/០៨៥ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ០៣ រូប ១២៦៧

១៦.០២.២០១២ - ព្រះរាជក្រឹត្យ នស/រកត/០២១២/០៨៦ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន និងមន្ត្រីរាជការ ចំនួន ១៨ រូប ១២៦៨

១៦.០២.២០១២ - ព្រះរាជក្រឹត្យ នស/រកត/០២១២/០៨៧ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ សប្បុរសជន ចំនួន ០២ រូប ១២៦៩

១៦.០២.២០១២ - ព្រះរាជក្រឹត្យ នស/រកត/០២១២/០៨៨ ស្ដីពី ការតែងតាំង ឯកឧត្តម តែន សេរីវឌ្ឍ ជា ទីប្រឹក្សាក្រសួងបរិស្ថាន មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ១២៧០

១៦.០២.២០១២ -ព្រះរាជក្រឹត្យ នស/រកត/០២១២/០៨៩ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតួបការ ចំពោះ ថ្នាក់ដឹកនាំ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ចំនួន ០២ រូប ១២៧១

១៦.០២.២០១២ -ព្រះរាជក្រឹត្យ នស/រកត/០២១២/០៩០ ស្តីពី ការតែងតាំង ឯកឧត្តម ពេជ ថន់ ជា ទីប្រឹក្សាអមក្រសួងសាធារណការ និង ដឹកជញ្ជូន មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ១២៧២

១៧.០២.២០១២ -ព្រះរាជក្រឹត្យ នស/រកត/០២១២/០៩១ ស្តីពី ការបញ្ចប់ភារកិច្ច ឯកឧត្តម ប្រាត់ ប៊ុនឡេវ ពីទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា មានឋានៈស្មើ រដ្ឋលេខាធិការ ១២៧៣

១៧.០២.២០១២ -ព្រះរាជក្រឹត្យ នស/រកត/០២១២/០៩២ ស្តីពីការតែងតាំង ឯកឧត្តម ស៊ុន ឃីម ជា ឧកញ៉ា ១២៧៤

២០.០២.២០១២ -ព្រះរាជក្រឹត្យ នស/រកត/០២១២/០៩៧ ស្តីពី ការតែងតាំង ឯកឧត្តម ជែត សារិន ជា ទីប្រឹក្សាអមក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានឋានៈស្មើ អគ្គនាយក ១២៧៥

II. រាជរដ្ឋាភិបាល

១. អនុក្រឹត្យ

២១.០២.២០១២ -អនុក្រឹត្យលេខ ២៨ អនក្រ.បក ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ ៩០០ ហិកតា ស្ថិតក្នុងតំបន់ដែនជម្រកសត្វព្រៃ ភ្នំណាមលៀវ ភូមិសាស្ត្រខេត្តមណ្ឌលគិរី និង និរាករណ៍អនុក្រឹត្យលេខ ៨៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១១ ១២៧៦

១៦.០២.២០១២ -អនុក្រឹត្យលេខ ២០៤ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១២៧៨

១៦.០២.២០១២ -អនុក្រឹត្យលេខ ២០៥ អនក្រ.តត ស្តីពី ការបញ្ចប់មុខតំណែងមន្ត្រីរាជការ ១២៧៩

១៧.០២.២០១២ -អនុក្រឹត្យលេខ ២០៦ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១២៨០

២០.០២.២០១២ -អនុក្រឹត្យលេខ ២០៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១២៨១

២០.០២.២០១២ -អនុក្រឹត្យលេខ ២០៨ អនក្រ.តត ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ ១២៨៧

២០.០២.២០១២ -អនុក្រឹត្យលេខ ២០៩ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១២៩៣

២១.០២.២០១២ -អនុក្រឹត្យលេខ ២១០ អនក្រ.តត ស្តីពី ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាតិ ១២៩៤

២១.០២.២០១២ -អនុក្រឹត្យលេខ ២១១ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ១២៩៥

២១.០២.២០១២ -អនុក្រឹត្យលេខ ២១២ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ១២៩៧

២១.០២.២០១២ -អនុក្រឹត្យលេខ ២១៣ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១២៩៩

p

២១.០២.២០១២ - អនុក្រឹត្យលេខ ២១៤ អនក្រ.តត ស្ដីពី ការតែងតាំងមុខតំណែងនាយនគរបាលជាតិ ១៣០១

២១.០២.២០១២ - អនុក្រឹត្យលេខ ២១៥ អនក្រ.តត ស្ដីពី ការជូនមេដាយសហមេត្រី ១៣០២

២១.០២.២០១២ - អនុក្រឹត្យលេខ ២១៦ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១៣០៣

២២.០២.២០១២ - អនុក្រឹត្យលេខ ២១៧ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ១៣០៤

២២.០២.២០១២ - អនុក្រឹត្យលេខ ២១៨ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ១៣០៦

២២.០២.២០១២ - អនុក្រឹត្យលេខ ២១៩ អនក្រ.តត ស្ដីពី ការជូនមេដាយសុវត្ថារា ១៣០៧

- អនុក្រឹត្យលេខ ២២០-២២១-២២២ អនក្រ.តត មិនទាន់បានទទួល

២២.០២.២០១២ - អនុក្រឹត្យលេខ ២២៣ អនក្រ.តត ស្ដីពី ការតែងតាំងមុខតំណែងនាយនគរបាលជាតិ ១៣០៨

២២.០២.២០១២ - អនុក្រឹត្យលេខ ២២៤ អនក្រ.តត ស្ដីពី ការតែងតាំងមុខតំណែងនាយនគរបាលជាតិ ១៣០៩

២២.០២.២០១២ - អនុក្រឹត្យលេខ ២២៥ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ១៣១០

២. សេចក្ដីសម្រេច

២១.០២.២០១២ - សេចក្ដីសម្រេចលេខ ១២ សសរ ស្ដីពី ការតែងតាំងមេបញ្ជាការរងកងពោះ
ដីកជញ្ជូនប្រតិភូជាន់ខ្ពស់ ១៣១១

III. ការងារបណ្ដាក្រសួង

១. ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

០៦.០២.២០១២ - ប្រកាសលេខ ១០៥ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហាត
អ៊ិនធើប្រាយ (ខេមបូឌា) ខូ អិលធីឌី បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ១៣១២

០៦.០២.២០១២ - ប្រកាសលេខ ១០៦ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន រូ ស៊ីង ហ្គាម៉ែន
បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ១៣១៦

០៦.០២.២០១២ - ប្រកាសលេខ ១០៧ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អេវើរហ្គ្រីន
ហ្គាមេន ខូ អិលធីឌី បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ១៣២០

០៦.០២.២០១២ - ប្រកាសលេខ ១០៨ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ដេខូរ៉ូ
(ខេមបូឌា) បង្កើតរោងចក្រ ផលិតសាឡុង (ធ្វើពីស្បែក) ១៣២៤

០៦.០២.២០១២ - ប្រកាសលេខ ១០៩ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន យាន ដា រ៉ុង ហ្វុង
(ខេមបូឌា) ផេកស្ទាយ ខូ អិលធីឌី បង្កើតរោងចក្រ ផលិត សម្លៀកបំពាក់
(កាត់ដេរ,ចាក់) ១៣២៨

១៣.០២.២០១២ - ប្រកាសលេខ ១៤៨ ឧរថ.បឧ.ប្រក ស្ដីពី នីតិវិធី និង ការចេញលិខិតបញ្ជាក់មុខ
សញ្ញា និង បរិមាណប្រើប្រាស់សារធាតុគីមី ១៣៣២

២_ឧីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៨-១២-២០១០ -លិខិតបញ្ជាក់លេខ ៩៥៦១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មេឃា ខនសាល់ធីង** ១៣៤៧

០៨-១២-២០១០ -លិខិតបញ្ជាក់លេខ ៩៥៦៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អង់គ្រា អ៊ិនធើណេសិនណល ហូលឌីង** ១៣៤៩

០៩-១២-២០១០ -លិខិតបញ្ជាក់លេខ ៩៥៦៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហាយដ្រូឡូជីគ សូសល អេនធើប្រាយ ខមភេនី លីមីធីត** ១៣៥១

០៩-១២-២០១០ -លិខិតបញ្ជាក់លេខ ៩៥៨០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **នីតូលីន អ៊ិនវេសមេន ខូ អិលធីឌី** ១៣៥៣

០៩-១២-២០១០ -លិខិតបញ្ជាក់លេខ ៩៥៨១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេចតីធី ម៉េរី** ១៣៥៥

០៩-១២-២០១០ -លិខិតបញ្ជាក់លេខ ៩៥៨២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ីស្ទីម អ៊ិនហ្វមេសិន ប្រ៊ីអ៊ាយធើរ (អេស.អាយ.ភី.)** ១៣៥៧

០៩-១២-២០១០ -លិខិតបញ្ជាក់លេខ ៩៥៨៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អាយ.ធី.អិម.អ៊ិនធើណេសិនណល ខបភើរេសិន** ១៣៥៩

០៩-១២-២០១០ -លិខិតបញ្ជាក់លេខ ៩៥៨៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេ អេហ្វ ស៊ី ឌីវេឡុបមេន** ១៣៦១

០៩-១២-២០១០ -លិខិតបញ្ជាក់លេខ ៩៥៨៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **តំពង់ស្តី ផ្លេនថេសិន** ១៣៦៣

០៩-១២-២០១០ -លិខិតបញ្ជាក់លេខ ៩៥៨៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ូណូ អ៊ិនធៀរ្យ គ្រុប** ១៣៦៥

០៩-១២-២០១០ -លិខិតបញ្ជាក់លេខ ៩៥៨៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជុង ហ្វុង ហ្វា អ៊ីមផត អិចផត** ១៣៦៧

ព្រះរាជក្រឹត្យ

នស/រកត/០២១២/០៧៩

ស្តីពី

ការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៣ ខែមករា ឆ្នាំ២០១២

ត្រាស់បង្គាប់

ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ត្រូវបានបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ដែលសរសេរជាអក្សរកាត់ថា **គ.អ.ឆ.ក.** ជាសេនាធិការផ្ទាល់របស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងនិងការអភិវឌ្ឍនៅតាមតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ប្រកបដោយនិរន្តរភាពនិងការទទួលខុសត្រូវ។

ជំពូកទី២
រចនាសម្ព័ន្ធ

មាត្រា ២.-

គ.អ.ឆ.ក. មានសមាសភាពដូចខាងក្រោម៖

- នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា		ប្រធានកិត្តិយស
- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់		ប្រធាន
- រដ្ឋមន្ត្រីក្រសួងបរិស្ថាន		អនុប្រធាន
- រដ្ឋមន្ត្រីក្រសួងទេសចរណ៍		អនុប្រធានអចិន្ត្រៃយ៍
- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី	០១ រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ	០១ រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងការពារជាតិ	០១ រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	០១ រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	០១ រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	០១ រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម	០១ រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន	០១ រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងផែនការ	០១ រូប	សមាជិក
- រដ្ឋលេខាធិការក្រសួងសុខាភិបាល	០១ រូប	សមាជិក
- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា		សមាជិក
- អគ្គស្នងការនគរបាលជាតិ		សមាជិក
- មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស		សមាជិក
- អភិបាលនៃគណៈអភិបាលខេត្តតំបន់ឆ្នេរសមុទ្រទាំង០៤		សមាជិក
- តំណាងគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ	០១ រូប	សមាជិក
- តំណាងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី	០១ រូប	សមាជិក
- តំណាងអគ្គនាយកដ្ឋានបច្ចេកទេសនៃក្រសួងបរិស្ថាន	០១ រូប	សមាជិក

- តំណាងអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្មនៃក្រសួង
  រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ០១ រូប សមាជិក
- អគ្គលេខាធិការ គ. អ.ឆ.ក. សមាជិក

សមាសភាពជាក់ស្តែងរបស់ **គ.អ.ឆ.ក.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

មាត្រា ៣.-

គ.អ.ឆ.ក. មានភារកិច្ចអនុវត្តការងាររបស់ខ្លួនលើឆ្នេរសមុទ្រ ដីចំណីឆ្នេរសមុទ្រ តំបន់ឈើកោងកាង កោះ ដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលតភ្ជាប់ទៅនឹងសមុទ្រ និងផ្ទៃទឹកដែលជាប់នឹងឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា លើទិដ្ឋភាពនគរូបនីយកម្ម បរិស្ថាន និងទេសចរណ៍។

មាត្រា ៤.-

ត្រូវបានបង្កើតអគ្គលេខាធិការដ្ឋានមួយជាសេនាធិការជូន **គ.អ.ឆ.ក.** សម្រាប់ដំណើរការការងារប្រចាំថ្ងៃ ហើយដែលមានទីស្នាក់ការនៅក្រសួងទេសចរណ៍។

ជំពូកទី៣
តួនាទីនិងភារកិច្ចរបស់គ.អ.ឆ.ក.

មាត្រា ៥.-

គ.អ.ឆ.ក. មានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព កម្មវិធី និងគម្រោងផ្សេងៗ ដែលទាក់ទងនឹងការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ
- រៀបចំបទដ្ឋានគតិយុត្តនិងគោលការណ៍ចាំបាច់នានា ដើម្បីធានាបាននូវការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍនៅតាមតំបន់ឆ្នេរសមុទ្រ ប្រកបដោយតម្លាភាព សមធម៌ និងនិរន្តរភាពបរិស្ថាន
- ពិនិត្យ បង្ការ និងចាត់វិធានការចាំបាច់ ដើម្បីទប់ស្កាត់រាល់សកម្មភាពអសកម្មទាំងឡាយដែលអាចប៉ះពាល់ដល់បរិស្ថាននិងធនធានធម្មជាតិនៅតាមតំបន់ឆ្នេរសមុទ្រ
- ពិនិត្យនិងវាយតម្លៃរាល់គម្រោងអភិវឌ្ឍនិងការអនុវត្តគម្រោងទាំងនេះនៅតាមតំបន់ឆ្នេរសមុទ្រឲ្យស្របតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល សម្រាប់ការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ
- ចូលរួមពិនិត្យនិងផ្តល់មតិជូនស្ថាប័នសមត្ថកិច្ច ចំពោះសំណើសុំវិនិយោគដែលពាក់ព័ន្ធលើឆ្នេរសមុទ្រ ដីចំណីឆ្នេរសមុទ្រ តំបន់ឈើកោងកាង កោះ ដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលតភ្ជាប់ទៅនឹងសមុទ្រ និងផ្ទៃទឹកដែលជាប់នឹងឆ្នេរសមុទ្រ
- ពិនិត្យ តាមដាន និងសម្របសម្រួលរាល់សកម្មភាពដែលកំពុងអនុវត្ត គ្រោងនឹងអនុវត្ត របស់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការជាតិនិងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិលនានា និងផ្នែកឯកជនដែលមាននៅតាមតំបន់ឆ្នេរសមុទ្រ ដើម្បីឲ្យការងារមានភាពរលូន ប្រកបដោយប្រសិទ្ធភាព និងធានាបាននូវនិរន្តរភាព
- បញ្ជ្រាបការយល់ដឹងដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ផ្នែកឯកជន និងគ្រប់ភាគីពាក់ព័ន្ធឲ្យយល់ដឹងអំពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ
- ធ្វើសហការជាមួយនឹងក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោកនិងស្ថាប័នអន្តរជាតិពាក់ព័ន្ធនានា ដើម្បីជំរុញការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ
- អប់រំ បណ្តុះបណ្តាលធនធានមនុស្ស ដើម្បីឆ្លើយតបនឹងតម្រូវការក្នុងការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ

- ធ្វើសហការជាមួយនឹងក្រសួង ស្ថាប័ន ផ្នែកឯកជន និងភាគីពាក់ព័ន្ធទាំងអស់ ដើម្បីសម្របសម្រួលការងារខាងលើឲ្យកាន់តែមានប្រសិទ្ធភាព
- រៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ **គ.អ.ឆ.ក.**
- ធ្វើរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំ ជូនរាជរដ្ឋាភិបាល
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

ជំពូកទី៤
ការប្រព្រឹត្តទៅរបស់ គ.អ.ឆ.ក.

មាត្រា ៦.-

គ.អ.ឆ.ក. ត្រូវប្រជុំយ៉ាងតិច២ដងក្នុង១ឆ្នាំតាមការអញ្ជើញរបស់ប្រធាន។

ក្នុងករណីចាំបាច់ ប្រធាន **គ.អ.ឆ.ក.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន មន្ត្រីជំនាញ អ្នកឯកទេស ឬផ្នែកឯកជនចូលរួមប្រជុំពិគ្រោះ ពិភាក្សាយោបល់ និងសិក្សាស្រាវជ្រាវលើរាល់បញ្ហាទាំងឡាយដែលទាក់ទងនឹងក្របខ័ណ្ឌការងាររបស់ខ្លួន។

ក្នុងករណីដែលប្រធានអវត្តមាន អនុប្រធានមួយរូបអាចដឹកនាំការប្រជុំជំនួសបានតាមការប្រគល់សិទ្ធិពីប្រធាន។

មាត្រា ៧.-

គ.អ.ឆ.ក. មានសិទ្ធិស្នើសុំកម្លាំងអន្តរាគមន៍ ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួនក្នុងករណីចាំបាច់។

មាត្រា ៨.-

គ.អ.ឆ.ក. អាចទទួលយកទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិឬអន្តរជាតិនានាមួយចំនួនតាមការចាំបាច់។

មាត្រា ៩.-

អគ្គលេខាធិការដ្ឋាននៃ **គ.អ.ឆ.ក.** ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ **គ.អ.ឆ.ក.** ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា ១០.-

គ.អ.ឆ.ក. មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងកិច្ចដំណើរការការងាររបស់ខ្លួន។

មាត្រា ១១.-

បទបញ្ជាផ្ទៃក្នុង របៀបរបប និងនីតិវិធីការងាររបស់ **គ.អ.ឆ.ក.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **គ.អ.ឆ.ក.**

ជំពូកទី៥
ប្រភពធនធាន

មាត្រា ១២.-

គ.អ.ធ.ក. មានថវិកាដោយឡែករបស់ខ្លួនដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងទេសចរណ៍។

គ.អ.ធ.ក. មានសិទ្ធិទទួលនិងគ្រប់គ្រងមូលនិធិដែលបានមកពីហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍនិងសហប្រតិបត្តិការអន្តរជាតិ និងពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

ជំពូកទី៦
អវសានប្បញ្ញត្តិ

មាត្រា ១៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ១៤.-

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០១២

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នរស. ១២០២.០៥៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

លេខៈ ៩៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ២០១២

អគ្គលេខាធិការរងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០២១២/០៧០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

ចំពោះ

លោកជំទាវ អ៊ុត ម៉ាលី

ដែលបានខិតខំបំពេញភារកិច្ចជូនជាតិមាតុភូមិ និងមានស្នាដៃល្អ
ក្នុងការចូលរួមចំណែកកសាងអភិវឌ្ឍន៍ប្រទេសជាតិ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

[illegible]. ១២០២.០៩៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២

លេខ: ៩៦ ច.ល
[illegible]សម្រាប់ចែក
រាជធានីភ្នំពេញ [illegible] ខែ កុម្ភៈ ឆ្នាំ២០១២
[illegible]រាជរដ្ឋាភិបាល
[illegible] សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០២១២/០៩១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឥស្សរជនជប៉ុន ចំនួន០៣រូប មានគុណបំណាច់និងស្នាដៃល្អក្នុងការផ្តល់ជំនួយ នូវសម្ភារៈ បច្ចេកទេស របស់រាជរដ្ឋាភិបាលជប៉ុនផ្តល់អោយស៊ីម៉ាក់ ក្នុងដំណាក់កាលទី៦ នៅទីបញ្ជាការកងឯកភាព បោសសំអាតមីនទី៦ របស់ស៊ីម៉ាក់ ខេត្តសៀមរាប

នូវ

ក-គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេរីវឌ្ឍន៍ :

ឯកឧត្តម ណាកាណូ ចូ (Nakano Joe)

ខ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-ឯកឧត្តម គូរូគី ម៉ាសាហ្វូមី (Kuroki Massafumi)

២-លោក ស៊ុយហ្ស៊ុយគី យ៉ាស៊ូយីរ៉ូ (Suzuki Yasuyiro)

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៦៨. ១២០២.០៩៦

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២

លេខៈ ៤១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ [illegible] ខែ កុម្ភៈ ឆ្នាំ២០១២
[illegible] រាជរដ្ឋាភិបាល

ស៊ុយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០២១២/០១៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១: ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ឯក នៃកងយោធពលខេមរភូមិន្ទ ជូនឯកឧត្តម ឧត្តមសេនីយ៍ទោ **ប៊ុន នី** អត្តលេខ ០០៤៣៧៨ ។

មាត្រា២: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៩.១២០២.០៥៧

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២

លេខ: ៧៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី
ស៊ុយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០២១២/០៥៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

តែងតាំង

លោក អ៊ុត ធី

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នាទ. ១២០២.០៥៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២

លេខ: ៩៣ ច.ល
ដើម្បីចម្លងចេញ
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ២០១២
[illegible]ទី១រាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០២១២/០៩៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ :ត្រូវបានតម្លើងឋានៈជូនជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចំនួន ០២ រូបមានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន ដោយពុំទទួលប្រាក់បៀវត្ស :

១-ឯកឧត្តម **ចាប មុំច**
២-ឯកឧត្តម **ឈៀ ស៊ីដារ៉ា**

មាត្រា២ :សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ :ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

[illegible]

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២

លេខ: ៩២ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ២០១២
[illegible] រាជរដ្ឋាភិបាល

p

ព្រះរាជក្រឹត្យ

នស/រកត/០២១២/០៩៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជនចំនួន០៣ រូប ដែលបានខិតខំកៀរគរ និងបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា នៅក្នុងខេត្តស្វាយរៀង

នូវ

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍:**
លោក **ម៉ក់ គុណធារី**

ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា:**
លោកវរសេនីយ៍ត្រី **មុត ចណ្ណ:**

គ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា:**
ព្រះតេជគុណ **រស់ ឌី**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរជ ១២០២.០៩០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២

លេខៈ ៩១ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១២
...ទីស្តីការគណៈរដ្ឋមន្ត្រី ...រាជរដ្ឋាភិបាល

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០២១២/០៧៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន និងមន្ត្រីរាជការចំនួន ១៨រូប ដែលបានលះបង់កំលាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយអភិវឌ្ឍន៍មូលដ្ឋាន លើគ្រប់វិស័យ និងជួយឧបត្ថម្ភដល់ប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់ និងភាពកបាទក្រហមខេត្ត នៅក្នុងខេត្តព្រះសីហនុ

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

១-លោកវរសេនីយ៍ទោ ចាន់ សារិន
២-លោកវរសេនីយ៍ទោ ស្រ៊ុន ទី
៣-លោកវរសេនីយ៍ត្រី មិត្ត សំអាត
៤-លោកវរសេនីយ៍ត្រី ជា តារា
៥-លោកវរសេនីយ៍ត្រី វ៉ែន ហុក
៦-លោកវរសេនីយ៍ត្រី កែវ សាម៉ុឌី
៧- លោកអនុសេនីយ៍ឯក អ៊ុក ស្រួយ
៨-លោកអនុសេនីយ៍ឯក ជា បុរិន្ទ
៩-លោកអនុសេនីយ៍ឯក ប្រាជ្ញ រិទ្ធថា
១០-លោកអនុសេនីយ៍ទោ ឱុយ សម្បត្តិ
១១-លោកអនុសេនីយ៍ទោ ជី មេខជន
១២-លោកអនុសេនីយ៍ទោ ប្លង់ សំអាន
១៣-លោកអនុសេនីយ៍ទោ អ៊ុន សោភ័ណ
១៤-លោក ផាត់ សារូន
១៥-លោក សរិទ្ធ សុខហួន
១៦-លោក ខាត់ គីមយឿន

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

១-លោកវរសេនីយ៍ទោ ឡុង ឆួ
២- លោកវរសេនីយ៍ត្រី ចាន់ សាហ៊ុត

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣៦៧.១២០២.០៩១

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២

លេខ ៩០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០១២
អគ្គលេខាធិការ[illegible]រាជរដ្ឋាភិបាល

[illegible]យ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០២១២/០៩៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជនចំនួន០២ រូប ដែលបានខិតខំកៀរគរ និងបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាង សមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា នៅក្នុងខេត្តសៀមរាប

នូវ

គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** :

១- ព្រះតេជគុណចន្ទត្ថេរ **លួច លៀត**

២- លោកជំទាវ **ស៊ាន ឈុនហេង ស៊ោង សារ៉ាត់**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

១១៧៣.១២០២.០៩២

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២

លេខ ៨៩ ប.ល
ដើម្បីចម្លងចែក
ភ្នំពេញ ថ្ងៃទី ២២ កុម្ភៈ ឆ្នាំ២០១២
រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកទំនាក់ទំនងរាជរដ្ឋាភិបាល

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០២១២/០៥៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម **តែន សេរីរដ្ឋា** ជាទីប្រឹក្សាក្រសួងបរិស្ថាន មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរស.១/១០២.០៩៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២

ច.ល
ផ្ញើរបញ្ជូនចែក
រាជធានីភ្នំពេញ [illegible] ខែ កុម្ភៈ ឆ្នាំ២០១២
[illegible]រដ្ឋាភិបាល
ទេយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០១១២/០៧៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
ដែលមានស្នាដៃល្អលើវិស័យប្រយុទ្ធប្រឆាំងគ្រឿងញៀន និងគុណបំណាច់ធំៗជាច្រើន
ក្នុងការចូលរួមចំណែកការពារសន្តិសុខ សណ្តាប់ធ្នាប់សង្គម ទទួលបានលទ្ធផលល្អប្រសើរ

នូវ

គ្រឿងឥស្សរិយយស ជាតូបការ :

- ឯកឧត្តមឧត្តមសេនីយ៍ឯក ឆូ ស៊ីន អត្តលេខ 0000៨៦
- ឯកឧត្តមឧត្តមសេនីយ៍ឯក លី គឹមឡុង អត្តលេខ 0៣៤២

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣១៩. ១/១០/២. ០៩៤

លេខ: ៥២ ប.ល
ដើម្បីឡកូខចែក

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១3 ខែ កុម្ភៈ ឆ្នាំ ២០១២

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ២០១២
អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០២១២/០៩០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម **ពេជ ជន់** ជាទីប្រឹក្សាអមក្រសួងសាធារណការ និងដឹកជញ្ជូន មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣១៧.១២០២.០៩៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២

លេខ: ៩៥ ប.ល
ជើងផ្ញើសូមចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ២០១២
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០២១២/០៩១

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី១ នីតិកាលទី៤ នាថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នីតិកាលទី៤
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់ **សម្ដេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានបញ្ចប់ភារកិច្ចឯកឧត្ដម **ប្រាក់ ម៉ុនឡៅ** ពីទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

មាត្រា ២ : សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៩៥.១២០២.០៩៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ កុម្ភៈឆ្នាំ ២០១២

លេខ: ៨៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្ដីទីរាជរដ្ឋាភិបាល
ស៊ុយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០២១២/០៩៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

តែងតាំង

ឯកឧត្តម ស៊ីន យឹម

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធារសា.១៧០២.០៩៧

ធ្វើនៅព្រះបរមរាជវាំង.ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២

លេខៈ ៥៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ២០១២
[illegible] មន្ត្រីទីស្តីការរាជរដ្ឋាភិបាល

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០២១២/០៩៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យលព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យលព្រះរាជក្រម លេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានទ្រង់យលសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានតែងតាំងឯកឧត្តម **ដែក សារិន** ជាទីប្រឹក្សាអមក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានឋានៈស្មើ **អគ្គនាយក** ។

មាត្រា ២: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរស.១២០២.១០២

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២

លេខ: ១០២ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០១២
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល

សុខា

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ ៥០០ហិកតា ស្ថិតក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំណាមលៀរ ភូមិសាស្ត្រខេត្តមណ្ឌលគិរី និង និរាករណ៍អនុក្រឹត្យលេខ ៨៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០១១

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឲ្យច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

  បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរការនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

  បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០១២ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជា តំបន់ប្រើប្រាស់ដោយចីរភាព

  បានឃើញអនុក្រឹត្យលេខ ៨៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០១១ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ ៥០០ហិកតាក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំណាមលៀរ ភូមិសាស្ត្រខេត្តមណ្ឌលគិរី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល។

p

សម្រេច

មាត្រា១៖

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ **៥០០ហិកតា** (ប្រាំរយហិកតា)ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំណាមលៀរ ភូមិសាស្ត្រខេត្តមណ្ឌលគិរី ក្រោមល័ក្ខខ័ណ្ឌសម្បទានដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម និងដំណាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមកាដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ០២ សជណ.គស ចុះថ្ងៃទី ០៣ ខែមករា ឆ្នាំ២០១២ របស់ទីស្តីការគណៈរដ្ឋមន្ត្រីជាឯកសារឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា២៖

ត្រូវបាននិរាករណ៍អនុក្រឹត្យលេខ ៨៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០១១ ស្តីពីការធ្វើអនុបយោគផ្ទៃដីចំនួន ៥០០ហិកតា ក្នុងដែនជម្រកសត្វព្រៃភ្នំណាមលៀរ ខេត្តមណ្ឌលគិរី ។

មាត្រា៣៖

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៤៖

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំ[illegible] កុម្ភៈ ឆ្នាំ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល

  ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

  ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី

  "ដើម្បីគោរពជូនជ្រាប"

  ដូចប្រការ ៤ ដើម្បីអនុវត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...២០៤...អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់មេបញ្ជាការកងទ័ពជើងគោក

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូននាយទាហាន ចំនួន ០៥ រូប ចំណុះយោធភូមិភាគទី៥ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

១-វរសេនីយ៍ត្រី	**ទ្រឹក**	**ណារ៉េត**	០៣៥២៣៣	នាយរងផ្នែកឯកទេសបច្ចេកទេស យោធភូមិភាគទី៥
២-វរសេនីយ៍ត្រី	**ម៉ុន**	**សុខឿន**	០១១៩៩៧	នាយផ្នែកបរិក្ខា ការិយាល័យទី៤ យោធភូមិភាគទី៥
៣-វរសេនីយ៍ត្រី	**ម៉ុត**	**ម៉ុនធឿត**	០១៥៨៩២	ជំនួយការបុគ្គលិក ការិយាល័យទី១ យោធភូមិភាគទី៥
៤-វរសេនីយ៍ត្រី	**ឡុង**	**ម៉ុនសេង**	០៣០២០៩	នាយរងផ្នែកសន្តិសុខផ្ទៃក្នុង ការិយាល័យទី១ យោធភូមិភាគទី៥
៥-វរសេនីយ៍ត្រី	**គង់**	**សារ៉េត**	០៧៧៤១២	នាយរងផ្នែកវិស្វកម្ម យោធភូមិភាគទី៥

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងមេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២០៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការបញ្ចប់មុខតំណែងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៨០០/១៥២ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា
- បានឃើញអនុក្រឹត្យលេខ ៦១ អនក្រ.តត ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីតែងតាំងមន្ត្រីរាជការ
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

មាត្រា ១ : ត្រូវបានបញ្ចប់មុខតំណែងឯកឧត្តម **ខួន តាំងលាង** ពីអគ្គលេខាធិការរង នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
ដូចមាត្រា ៣
រាជកិច្ច
ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២០៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយថ្នាក់ការងារ** ជូនបុគ្គលិកអង្គការក្រៅរដ្ឋាភិបាល ចំនួន០៤រូប ដែលមានស្នាដៃល្អដោយបានធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីជួយដល់ប្រជាពលរដ្ឋដែលរងគ្រោះដោយទឹកជំនន់ កាលពីឆ្នាំ២០១១ នៅក្នុងរាជធានី និងខេត្ត ចំនួន១៦ ដូចមានរាយនាមខាងក្រោម ៖

១-លោក	Marc Hall	នាយកប្រចាំប្រទេស អង្គការ RDI
២-លោក	Andrew D.Miller	ប្រធានកម្មវិធី អង្គការ MCC
៣-លោក	MD.IQBAL AHMED	ប្រធានកម្មវិធី អង្គការមុស្លីមអេដកម្ពុជា
៤-លោក	Rick Degraaf	ទីប្រឹក្សាប្រចាំប្រទេស អង្គការ CRWRC

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ... ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

ព្រះរាជាណាចក្រកម្ពុជា គណៈរដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២០៧ . អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងការប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១ .-

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ចំនួន ១២៧ គ្រឿង ជូននាយទាហាន នាយទាហានរង និងពលទាហាន នាយកដ្ឋានវិស្វកម្ម អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ ដែលមានស្នាដៃក្នុងការកសាងសាលារៀន មន្ទីរពេទ្យ ផ្លូវ ស្ពាន និងតបណ្តាញ ទឹក នៅចំណុចខ្ពស់ តាមព្រំដែនកម្ពុជា ថៃ ទទួលបានលទ្ធផលល្អ ដូចមានរាយនាមខាងក្រោម ៖

ក.-មេដាយមាសការងារ

១-	អនុសេនីយ៍ឯក	**ហ៊ឹម រក្សា**	អត្តលេខ ០៣៩៥៤២	ជំនួយការ ការិយាល័យផែនការ
២-	អនុសេនីយ៍ឯក	**ពោជ សារិន**	អត្តលេខ ០៣១៣៥៧	នាយផ្នែករបៀប
៣-	អនុសេនីយ៍ឯក	**ឥន្ទ វណ្ណារិទ្ធ**	អត្តលេខ ១៩៨៨៥០	នាយផ្នែកគ្រប់គ្រងអគ្គិសនី-ទឹក
៤-	អនុសេនីយ៍ឯក	**ទិន ម៉ៅ**	អត្តលេខ ០២៥១៤៦	បើកបរគ្រឿងចក្រ

p

៥-	អនុសេនីយ៍ឯក	**ជាង នីណា**	អត្តលេខ ១៩៨៨២១	មេបញ្ជាការរង កងអនុសេនាធំទី៣
៦-	អនុសេនីយ៍ឯក	**មុំ និមល**	អត្តលេខ ១៥១៨៣២	ជ-គ្រប់គ្រងគ្រឿងចក្រ-គ្រឿងយន្ត
៧-	អនុសេនីយ៍ឯក	**សោម ចាន់**	អត្តលេខ ០១៩១៨៩	ជំនួយការវាស់ស្ទង់
៨-	អនុសេនីយ៍ឯក	**អ៊ុន សុណៃត**	អត្តលេខ ០២៨៧១៩	ជំនួយការលេខាធិការដ្ឋាន
៩-	អនុសេនីយ៍ឯក	**ម៉ម ប៊ុនថា**	អត្តលេខ ០៨៣១៩៨	ជំនួយការនាយកដ្ឋាន
១០-	អនុសេនីយ៍ឯក	**អ៊ុច គងដែនតា**	អត្តលេខ ១៩៨៦៩២	ជំនួយការភស្តុភារកងគ្រឿងចក្រ
១១-	អនុសេនីយ៍ឯក	**ស៊ឿន វិសាល**	អត្តលេខ ០៨៨៨៥០	ជំនួយការការិ.បច្ចេកទេស
១២-	អនុសេនីយ៍ឯក	**ហ៊ុច ខ៊ែត**	អត្តលេខ ០៨៨៨៦៦	ជំនួយការការិ.គ្រប់គ្រង
១៣-	អនុសេនីយ៍ឯក	**ពូន វិចិត្រ**	អត្តលេខ ០៨៨៥០៣	ជំនួយការការិ.គ្រប់គ្រង
១៤-	អនុសេនីយ៍ឯក	**មាស រដ្ឋា**	អត្តលេខ ១៩៨៧២០	នាយផ្នែកបើកចែកការិ.សំភារៈ
១៥-	អនុសេនីយ៍ឯក	**ចាន់ ស៊ីណា**	អត្តលេខ ១០៨៧២០	ជំនួយការកងគ្រឿងចក្រ១៧៨
១៦-	អនុសេនីយ៍ឯក	**ហែម សុភ័ក្រ**	អត្តលេខ ១៩៨៧២១	ជំនួយការហិរញ្ញវត្ថុ
១៧-	អនុសេនីយ៍ឯក	**តាន់ សុផេន**	អត្តលេខ ១៩៨៨៦០.	នាយផ្នែកបូកសរុប
១៨-	អនុសេនីយ៍ឯក	**ខួច ខួន**	អត្តលេខ ១៩៨៧០៥	នាយផ្នែកវាស់ស្ទង់
១៩-	អនុសេនីយ៍ឯក	**លី ពុទ្ធី**	អត្តលេខ ០៥៨២០១	ជំនួយការលេខាធិការដ្ឋាន
២០-	អនុសេនីយ៍ឯក	**សម មុនីរក្សី**	អត្តលេខ ១១៣៨៣៩	ជ-ផែនការ កងគ្រឿងចក្រ១៧៨
២១-	អនុសេនីយ៍ឯក	**ស មករា**	អត្តលេខ ០៨៨៨១៦	នាយរងសេនាធិការកងគ្រឿងចក្រ
២២-	អនុសេនីយ៍ទោ	**សយ មុរ៉ា**	អត្តលេខ ១៩៨៧៦៨	ជំនួយការការិ.បច្ចេកទេស
២៣-	អនុសេនីយ៍ទោ	**ណាំ វិបុល**	អត្តលេខ ០៥៨២៨៩	ជំនួយការការិ.សំភារៈ
២៤-	អនុសេនីយ៍ទោ	**ម៉ន ចណ្ណារៈ**	អត្តលេខ ០៥៨២៩៨	ជំនួយការការិ.គ្រប់គ្រង
២៥-	អនុសេនីយ៍ទោ	**ហាក់ សុខនាគ**	អត្តលេខ ១៩៨៨២៦	ជំនួយការហិរញ្ញវត្ថុកងគ្រឿងចក្រ
២៦-	អនុសេនីយ៍ត្រី	**ម៉ី សក្ខដា**	អត្តលេខ ១៩៨៨៥៤	ជំនួយការការិ.បច្ចេកទេស
២៧-	នាយចំនង់	**សន សុធា**	អត្តលេខ ១៩៨៨៣៣	ជំនួយការការិ.ផែនការ
២៨-	នាយចំនង់	**សាំ បុណ្ណវឌ្ឍ**	អត្តលេខ ១៩៨៧៥៧	បើកបររថយន្ត

p

២៩-	នាយចំនង់	**សៅ សុផល**	អត្តលេខ ១៩៨៧៦៣	បើកបររថយន្ត
៣០-	នាយចំនង់	**ឆាយ វិចិត្រ**	អត្តលេខ ១៩៨៨១២	បើកបររថយន្ត
៣១-	ព្រិន្ទបាលឯក	**គុល ចន្ឋា**	អត្តលេខ ១៩៨៨៣៩	បើកបររថយន្ត
៣២-	ព្រិន្ទបាលឯក	**ឡឿក សុខុន**	អត្តលេខ ១៩៨៧៧៦	បើកបររថយន្ត
៣៣-	ព្រិន្ទបាលឯក	**អ៊ឹម សុតី**	អត្តលេខ ១៩៨៨២៩	បើកបររថយន្ត
៣៤-	ព្រិន្ទបាលឯក	**អែម គីមរឆន**	អត្តលេខ ១៩៨៧៨៥	បើកបររថយន្ត
៣៥-	ព្រិន្ទបាលឯក	**ម៉ូច សារី**	អត្តលេខ ១៩៨៧២៥	ជំនួយការបុគ្គលិក
៣៦-	ព្រិន្ទបាលទោ	**សុខ ម៉ិនធឿន**	អត្តលេខ ១៩៨៧៣២	កងការពារ
៣៧-	ព្រិន្ទបាលទោ	**អៀង ឧត្តរា**	អត្តលេខ ១៩៨៧៤១	បើកបរប៊ុលដូហ្សែរ
៣៨-	ព្រិន្ទបាលទោ	**ម៉ា ណាង**	អត្តលេខ ១៩៨៧៣៣	បើកបរអេស្កាវ៉ាទ័រ
៣៩-	ព្រិន្ទបាលទោ	**ហែម ម៉ាន់**	អត្តលេខ ១៩៨៧៣៧	បើកបរប៊ុលដូហ្សែរ
៤០-	ព្រិន្ទបាលទោ	**ធួន ពុទ្ធិ**	អត្តលេខ ១៩៨៧៨៨	បើកបររ៉ូឡូ
៤១-	ព្រិន្ទបាលទោ	**ប្រាក់ សុវណ្ណ**	អត្តលេខ ១៩៨៧៥០	បើកបរនីវ៉ាឡឺ
៤២-	ព្រិន្ទបាលទោ	**ស៊ិន ច័ន្ទតារា**	អត្តលេខ ១៩៨៧៣៩	ជាងជួសជុលរថយន្ត-គ្រឿងចក្រ
៤៣-	ពលបាលឯក	**ធួន ពិសិដ្ឋ**	អត្តលេខ ១៩៨៧៦៥	បើកបររថយន្ត
៤៤-	ពលបាលឯក	**ទ្រិល ម៉ិនហៀង**	អត្តលេខ ១៩៨៧៩៥	បើកបររថយន្ត
៤៥-	ពលបាលឯក	**ឱុយ ដារ៉ា**	អត្តលេខ ១៩៨៧៧១	បើកបររថយន្ត
៤៦-	ពលបាលឯក	**ឈុន មន្នីរ**	អត្តលេខ ១៩៨៧៨៧	បើកបររថយន្តស្ទូច
៤៧-	ពលបាលឯក	**ឱុច ធឿន**	អត្តលេខ ១៩៨៧៨៩	បើកបររថយន្តស្ទូច
៤៨-	ពលបាលឯក	**មុត សុខា**	អត្តលេខ ១៩៨៧៩១	បើកបរប៊ុលដូហ្សែរ
៤៩-	ពលបាលឯក	**ចាន់ ជាតិ**	អត្តលេខ ១៩៨៨៣១	បើកបរប៊ុលដូហ្សែរ
៥០-	ពលបាលឯក	**ម៉ី ស្រ៊ុន**	អត្តលេខ ១៩៨៨៣២	បើកបររថយន្ត
៥១-	ពលបាលឯក	**ឌុត សារី**	អត្តលេខ ១៩៨៨២៤	បើកបរនីវ៉ាឡឺ
៥២-	ពលបាលឯក	**គង់ យេង**	អត្តលេខ ១៩៨៨០៦	បើកបររ៉ូឡូ
៥៣-	ពលបាលឯក	**សុខ សាលី**	អត្តលេខ ១៩៨៨៥១	ជាងសំនង់
៥៤-	ពលបាលឯក	**ស៊ី សុធា**	អត្តលេខ ១៩៨៨១១	បើកបររថយន្ត
៥៥-	ពលបាលឯក	**ម៉េង ចន្ថា**	អត្តលេខ ១៩៨៧៦៥	បើកបររថយន្ត
៥៦-	ពលបាលឯក	**ទ៊ឹល ម៉ិនណាត**	អត្តលេខ ១៩៨៨៦៩	ជំនួយការលេខាធិការដ្ឋាន
៥៧-	ពលបាលទោ	**ម៉ី ម៉ៅ**	អត្តលេខ ១៩៨៨៨៧	បើកបរនីវ៉ាឡឺ

p

៥៨- ពលទោ ប៉ីន ឈួន អត្តលេខ ២២៨៧៨៦ បើកបររថយន្ត
៥៩- ពលទោ គឿ ឫទ្ធី អត្តលេខ ២២៨៧១៨ បើកបរម៉ូតូហ្វៀរ
៦០- ពលទោ គី វ៉ាស៊ី អត្តលេខ ២២៨៧៣៧ បើកបរម៉ូតូហ្វៀរ

ខ. មេដាយប្រាក់ការងារ

១- អនុសេនីយ៍ទោ ដួង ប្រុស អត្តលេខ ០៨៣១៨៣ បំពេញការលេខាធិការដ្ឋាន
២- អនុសេនីយ៍ទោ យឹម ឡូច អត្តលេខ ១៩៨៧២៧ ជំនួយការបុគ្គលិក
៣- អនុសេនីយ៍ត្រី ផង់ ផាន់ណា អត្តលេខ ១៩៨៧៧៧ បើកបររថយន្ត
៤- អនុសេនីយ៍ត្រី នី សុផល អត្តលេខ ១៩៨៨៦៧ គិលានុបដ្ឋាកបឋម
៥- នាយចំនង់ ម៉ម រដ្ឋា អត្តលេខ ១៩៨៧០៤ ជំនួយការរបៀប
៦- នាយចំនង់ សន ឧត្តណ្ណារី អត្តលេខ ១៩៨៨៣៤ ជំនួយការភស្តុភារគេងគ្រឿងចក្រ
៧- នាយចំនង់ ដួង សុផាន់ អត្តលេខ ១៩៨៧៥១ បើកបររថយន្ត
៨- នាយចំនង់ ដួង សុផាត់ អត្តលេខ ១៩៨៧៨២ បើកបររថយន្ត
៩- នាយចំនង់ ដួង ចណ្ណះ អត្តលេខ ១៩៨៨០៧ បើកបរអេស្កាវ៉ាទ័រ
១០- នាយចំនង់ ជុំ ពុធ អត្តលេខ ១៩៨៨៦១ ជាងអគ្គិសនី
១១- នាយចំនង់ អ៊ុត ណុល អត្តលេខ ១៩៨៨៧៩ ជំនួយការភស្តុភារគេងគ្រឿងចក្រ
១២- នាយចំនង់ ឡាត់ ណេត អត្តលេខ ១៩៨៨៨៤ ជាងអគ្គិសនី
១៣- ព្រិន្ទបាលឯក អ៊ួន ផាំរុទ អត្តលេខ ១៩៨៨៥៨ ជាងជួសជុលរថយន្ត-គ្រឿងចក្រ
១៤- ព្រិន្ទបាលទោ វ៉ន់ គីម អត្តលេខ ១៩៨៧៨៦ បើកបរអេស្កាវ៉ាទ័រ
១៥- ពលបាលឯក គង់ សាវ៉ាត់ អត្តលេខ ១៩៨៨១០ បើកបររថយន្ត
១៦- ពលបាលឯក ពុំ វ៉ាគីន អត្តលេខ ១៩៨៨៧០ បើកបររថយន្ត
១៧- ពលបាលឯក ពុំ សម្បត្តិ អត្តលេខ ១៩៨៨០៤ បើកបររថយន្ត
១៨- ពលបាលឯក សាន ដាវ៉ា អត្តលេខ ១៩៨៨៥៧ ជាងសំនង់
១៩- ពលបាលឯក ចៀម ចាន់ អត្តលេខ ១៩៨៨២៥ បើកបរអេស្កាវ៉ាទ័រ
២០- ពលបាលទោ ប៉ុក គីមនាថ អត្តលេខ ១៩៨៨៨៥ បើកបររថយន្ត
២១- ពលទោ សាត សុភក្តិ អត្តលេខ ២២៨៧៥៥ បើកបររថយន្ត
២២- ពលទោ ប៊ុន ស៊ាងហ៊ត់ អត្តលេខ ២២៨៧៨១ បើកបររថយន្ត
២៣- ពលទោ គី រិទ្ធី អត្តលេខ ២២៨៧៣៨ បើកបររថយន្ត
២៤- ពលទោ គុល ចាន់ដារុធ អត្តលេខ ២២៨៧៣៩ បើកបររថយន្ត
២៥- ពលទោ ប៉ុក ស៊ីថាន អត្តលេខ ២២៨៧២៥ បើកបររថយន្ត
២៦- ពលទោ ចាន់ រិទ្ធី អត្តលេខ ២២៨៧២២ បើកបររថយន្ត
២៧- ពលទោ ឡូច ធឿន អត្តលេខ ២២៨៧១៧ បើកបររថយន្ត

p

២៨-	ពលទោ	**មាន ច័ន្ទដារុណ**	អត្តលេខ ២២៨៧១៩	បើកបររថយន្ត
២៩-	ពលទោ	**សន ចណ្ណារ័ត្ន**	អត្តលេខ ២២៨៧១៦	កុំព្យូទ័រ
៣០-	លោកស្រី	**កែម ផារី**	ចុងភៅ	

គ.មេដាយសំរិទ្ធការងារ

១-	នាយចំនង់	**ពិន ម៉ានិត**	អត្តលេខ ១៩៨៧៩៣	ជំនួយការនាយកដ្ឋាន
២-	ព្រិន្ទបាលឯក	**ចាំង ប៊ុនណាត**	អត្តលេខ ១៩៨៧១៥	ជំនួយការលេខាធិការដ្ឋាន
៣-	ព្រិន្ទបាលឯក	**សុខ សាម៉េន**	អត្តលេខ ១៩៨៧៤៧	បើកបររ៉ឺម៉ូ
៤-	ព្រិន្ទបាលឯក	**ម៉ែន ពុទ្ធល័ក្ខ**	អត្តលេខ ១៩៨៧៧៤	បើកបររថយន្ត
៥-	ព្រិន្ទបាលឯក	**ម៉ែន ទ្រី**	អត្តលេខ ១៩៨៧៧៨	បើកបររថយន្ត
៦-	ព្រិន្ទបាលឯក	**ហ៊ួយ ចន្ថា**	អត្តលេខ ១៩៨៧៩៧	បើកបររថយន្ត
៧-	ព្រិន្ទបាលឯក	**អុន គឹម**	អត្តលេខ ១៩៨៨០០	បើកបររថយន្ត
៨-	ព្រិន្ទបាលឯក	**ពៅ ចក់**	អត្តលេខ ១៩៨៨០៩	បើកបររថយន្ត
៩-	ព្រិន្ទបាលឯក	**ដេត ទូច**	អត្តលេខ ១៩៨៨៦៣	ជាងអគ្គិសនី
១០-	ព្រិន្ទបាលឯក	**សូ គាស់**	អត្តលេខ ១៩៨៧៦៧	បើកបររថយន្ត
១១-	ព្រិន្ទបាលឯក	**ឆេត កោសល**	អត្តលេខ ១៩៨៨៨៦	បើកបរអេស្កាវ៉ាទ័រ
១២-	ព្រិន្ទបាលឯក	**សោម សំណាង**	អត្តលេខ ១៩៨៨៨៨	បើកបររថយន្ត
១៣-	ព្រិន្ទបាលទោ	**ទ្រី សុខឡេង**	អត្តលេខ ០៧៧៩៨១	ជំនួយការរបៀប
១៤-	ព្រិន្ទបាលទោ	**តាត់ ចន្ថា**	អត្តលេខ ១៩៨៧៣៦	បើកបរអេស្កាវ៉ាទ័រ
-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០: រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។/.

p

ប្រការ១១: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

ប្រការ១២: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

ប្រការ១៤: ប្រកាសលេខ ៩៥០ឧរថ.កឧ.ប្រក ចុះថ្ងៃទី១៥.១២.២០០៥ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន ហាតអ៊ិនធើប្រាយ (ខេមបូឌា) ខូ អិលធីឌី ដែលមានទីតាំងស្ថិតនៅ ភូមិអង្គ ឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្តាល ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ១៥: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងខេត្តកណ្តាល និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១៦: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន
ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
ក្រសួងបរិស្ថាន
ក្រសួងពាណិជ្ជកម្ម
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
សាលារាជធានីភ្នំពេញ
សាលាខេត្តកណ្តាល
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត
ឯកសារ កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry, Mines and Energy

លេខ : ២៧៦ ឧស៊ក.កឧ-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី៩៦ ខែកុម្ភៈ ឆ្នាំ២០១២

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ ២១៧១/៩៧ ក អ ក ចុះថ្ងៃទី២២.០៧ ១៩៩៧ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន រូ ស៊ីង ហ្គាមែន ចុះថ្ងៃទី១៣.១២.២០១១

សម្រេច

ប្រការ១: អនុញ្ញាតឲ្យក្រុមហ៊ុន រូ ស៊ីង ហ្គាមែន (ROO HSING GARMENT CO., LTD) តំណាងដោយ លោក CHEN HSING HUNG សញ្ជាតិចិន(តៃវ៉ាន់) អាយុ៥៤ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 13385057 ចុះថ្ងៃទី២៩.១១.២០០៥ មានអាសយដ្ឋានបច្ចុប្បន្ន៖ 13F 4, 57 Fu Hsing N Road Taipei, Taiwan ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម ៖

ឈ្មោះផលិតផល	**លេខចុះបញ្ជីផលិតផល** ISIC Rev.4 Code
សម្លៀកបំពាក់	១៤១០

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ ៨៥៥-២៣-២១១១៤១ ទូរសារ ៨៥៥-២៣ ៤២៨២៦៣
45 Preah Norodom Boulevard Khan Daun Penh Phnom Penh Phone 855 23 211141 Fax 855-23-428263

ផ្លាកឈ្មោះរោងចក្រ៖ *" រោងចក្រកាត់ដេរ រ៉ូស៊ីង ហ្គាម៉ែន "*

ទីតាំងរោងចក្រ៖ *"ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ "*

ប្រការ២: -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤: ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

ប្រការ៥: ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចដូល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

ប្រការ៦: ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

p

ប្រការ៧: -មុនចាប់ផ្តើមដំណើរការពេងចក្រ ម្ចាស់ពេងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការពេងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការពេងចក្រនឹងត្រូវចេញឲ្យម្ចាស់ពេងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់ពេងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់ពេងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់ពេងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាបច្ចេកទេស(?) ...

ពេងចក្រប្រចាំ ០៣ ឆ្នាំ ។

ប្រការ៨: -ម្ចាស់ពេងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការពេងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងពេងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់ពេងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការពេងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការពេងចក្រ ហើយម្ចាស់ពេងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

ប្រការ៩: -ម្ចាស់ពេងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់ពេងចក្រ នឹងត្រូវទទួលទោសបញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងពេងចក្រ និងសិប្បកម្ម ។

ប្រការ១០: រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។/.

p

ប្រការ១១: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

ប្រការ១២: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

ប្រការ១៤: ប្រកាសលេខ ១០៩៦ ឧក.ប្រក ចុះថ្ងៃទី២៩.១២.១៩៩៧ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន វ៉ូ ស៊ីង ហ្គាម៉ែន ត្រូវចាត់ទុក ជានិរាករណ៍។

ប្រការ១៥: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១៦: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន:
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
ឯកសារ-កាលប្បវត្តិ

p

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ២០៣៧ ឧរថ.ភិទ.ប្រក.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើ ច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញលិខិតលេខ៥៩០/៩៥ គ.វ.ក ចុះថ្ងៃទី០៦.០៧.១៩៩៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-បានឃើញលិខិតលេខ៣៦៣៨ /០៥ គ.វ.ក ចុះថ្ងៃទី២៨.១០.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-បានឃើញលិខិតលេខ១៦៥១ឧរថកឧ.លស ចុះថ្ងៃទី២៩.១០.២០០១ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន អេវើរគ្រីន ហ្គាមេន ខូ អេលធីឌី ចុះថ្ងៃទី០៨.០១.២០១២

សម្រេច

ប្រការ១: អនុញ្ញាតឲ្យក្រុមហ៊ុន អេវើរគ្រីន ហ្គាមេន ខូ អេលធីឌី (EVERGREEN GARMENT CO., LTD.) តំណាងដោយ លោក PARK CHAN WON សញ្ជាតិកូរ៉េ អាយុ៥៨ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 7116425 ចុះថ្ងៃទី១៩.០៩.២០០៦ មានអាសយដ្ឋានបច្ចុប្បន្ន៖ # 408 Dong 1903 Ho, Dong San Sam Sung lem an APT, Dang San Dong, Yeong Dung Po Gu,Seoul, Korea. ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម ៖

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១. ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard. Khan Daun Penh. Phnom Penh. Phone : 855-23-211141 Fax 855-23-428263

ឈ្មោះផលិតផល	**លេខចុះបញ្ជីផលិតផល** ISIC Rev.4 Code
សម្លៀកបំពាក់	១៤១០

ផ្លាកឈ្មោះរោងចក្រ ៖ *" រោងចក្រកាត់ដេរសម្លៀកបំពាក់ អេហ្វ៊ើរគ្រីន ហ្គាមេន "*
ទីតាំងរោងចក្រ ៖ *" ផ្លូវជាតិលេខ៥ ភូមិមិត្តភាព សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ "*

ប្រការ២: -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាននូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណតក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាសរោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមវាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាសរោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤: ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្របសកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបសខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

ប្រការ៥: ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

p

ប្រការ៦: ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

ប្រការ៧: មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

ប្រការ៨: -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

ប្រការ៩: -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៥៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០: រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

ប្រការ១១: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

ប្រការ១២: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

ប្រការ១៤: ប្រកាសលេខ ៣៨៨ ឧក.ប្រក ចុះថ្ងៃទី២០.០៥.១៩៩៦ របស់ក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់នាំចេញ របស់ក្រុមហ៊ុន យីង វ៉ា កាំបូឌីយ៉ា ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ១៥: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន ។

ប្រការ១៦: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

ចម្លងជូន:
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ១០៨ ឧរ៥.គរ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១២

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ៦៣ /១១ គ.វ.ក ចុះថ្ងៃទី១៧.០១.២០១១ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-បានឃើញលិខិតលេខ១៥៣២ /១១ គ.វ.ក ចុះថ្ងៃទី១៣.០៧.២០១១ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ដេខ្សូរ៉ (ខេមបូឌា) ចុះថ្ងៃទី២៥.០៧.២០១១

<u>ស ម្រេ ច</u>

<u>ប្រការ១:</u> អនុញ្ញាតឲ្យក្រុមហ៊ុន ដេខ្សូរ៉ (ខេមបូឌា) (DeCoro (CAMBODIA) Co., Ltd.) តំណាងដោយលោក Luca Ricci សញ្ជាតិអ៊ីតាលី អាយុ៤៧ឆ្នាំ កាន់លិខិតឆ្លងដែនលេខ Y528113 ចុះថ្ងៃទី ០៨.១២.២០០៥ មានអាសយដ្ឋានបច្ចុប្បន្ន៖ Via Rio Rose 890 Bertinoro 47032 Forli, Italy. ជាម្ចាស់ រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម ៖

មុខផលិតផល	**លេខចុះបញ្ជីផលិតផល** ISIC Rev.4 Code
សាឡុង (ធ្វើពីស្បែក)	៣១០០

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

p

ផ្លាកឈ្មោះរោងចក្រ៖ *"រោងចក្រផលិតគ្រឿងសង្ហារិម ដេខ្សី (ខេមបូឌា)"*
ទីតាំងរោងចក្រ ៖ *" ផ្លូវជាតិលេខ៤ ភូមិថ្លែល ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ "*

ប្រការ២: -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤: ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

ប្រការ៥: ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចដូរ ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

ប្រការ៦: ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

p

ប្រការ៧. -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្ម ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្ម រោងចក្រប្រចាំ ០៣ ឆ្នាំ ។

ប្រការ៨. -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

ប្រការ៩. -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០. រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។/.

ប្រការ១១: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

ប្រការ១២: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

ប្រការ១៤: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១៥: ប្រកាសនេះមានអនុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ចម្លងជូន.
ទីស្តីការគណៈរដ្ឋមន្ត្រី
រាជកិច្ច
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
ក្រសួងបរិស្ថាន
ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
សាលាខេត្តកំពង់ស្ពឺ
"ដើម្បីជូនជ្រាប"
ដូចប្រការ១៤ "ដើម្បីអនុវត្ត"
ឯកសារ កាលប្បវត្តិ

រដ្ឋមន្ត្រី

ស៊ុយ_សែម

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ: ១០៩ ឧ.ស.ក-កឧ-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០១២

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ២៥៥៦/១១ គ.វ.ក ចុះថ្ងៃទី០៣.១១.២០១១ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន យាន ដា រ៉ុង ហ្វុង (ខេមបូឌា) ថេកស្ទាយ ខូ អិលធីឌី ចុះថ្ងៃទី១៥.០៨.២០១១

សម្រេច

ប្រការ១: អនុញ្ញាតឲ្យក្រុមហ៊ុន យាន ដា រ៉ុង ហ្វុង (ខេមបូឌា) ថេកស្ទាយ ខូ អិលធីឌី (YUAN DA RONG FONG (CAMBODIA) TEXTILE Co., Ltd.) តំណាងដោយ លោក FENG CHUSHAN សញ្ជាតិចិន អាយុ៣៩ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G24093563 ចុះថ្ងៃទី២៧.០៧.២០០៧ មានអាសយដ្ឋានបច្ចុប្បន្ន: Guangdong, China ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម៖

ឈ្មោះផលិតផល	**លេខចុះបញ្ជីផលិតផល** ISIC Rev.4 Code
សម្លៀកបំពាក់ (កាត់ដេរ, ចាក់)	១៤១០

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone 855 23 211141 Fax 855 23 428263

ផ្លាកឈ្មោះរោងចក្រ ៖ *" រោងចក្រកាត់ដេរ និងចាក់សម្លៀកបំពាក់ យាន ជា រ៉ុង ហ្វុង (ខេមបូឌា) ថេកស្តាយ ខូ អិលធីឌី "*

ទីតាំងរោងចក្រ ៖ *" ភូមិត្រពាំងអង្គ សង្កាត់កោះក្រៅ ក្រុងដូនកែវ ខេត្តតាកែវ "*

ប្រការ២: -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: -ម្ចាសរោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤: ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

ប្រការ៥: ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណតដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចចូល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

ប្រការ៦: ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។/.

p

ប្រការ៧: -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់តម្លៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

ប្រការ៨: -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

ប្រការ៩: -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅពេលដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០: រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។/.

p

ប្រការ១១: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាម មាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

ប្រការ១២: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

ប្រការ១៤: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តតាកែវ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១៥: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន

ទីស្តីការគណៈរដ្ឋមន្ត្រី

រាជកិច្ច

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

ក្រសួងពាណិជ្ជកម្ម

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

សាលាខេត្តតាកែវ

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៤ "ដើម្បីអនុវត្ត"

-ឯកសារ កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry, Mines and Energy

លេខ : ០៤៨ ឧរម.បឧ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែ កុម្ភៈ ឆ្នាំ ២០១២

ប្រកាស

ស្តីពី

នីតិវិធី និងការចេញលិខិត

បញ្ជាក់មុខសញ្ញា និងបរិមាណប្រើប្រាស់សារធាតុគីមី

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៦ប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០៧ប្រកាសឲ្យប្រើច្បាប់ស្តីពីស្តង់ដារកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៥ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មការត្រួតពិនិត្យគ្រឿងញៀន
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការដាក់ឲ្យប្រើប្រាស់ទំនិញហាមឃាត់ និងទំនិញជាប់កំរិតកំណត់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃវិទ្យាស្ថានស្តង់ដារកម្ពុជា

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣

45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

- បានឃើញអនុក្រឹត្យលេខ ១០៨ អនក្រ.បក ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៩ ស្ដីពីការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី
- សេចក្ដីជូនដំណឹងលេខ ១៦៩៥ សជណ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៨ ស្ដីពីលទ្ធផលនៃវេទិការាជរដ្ឋាភិបាលផ្នែកឯកជនលើកទី ១៤ នាថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៨
- បានឃើញប្រកាសអន្តរក្រសួងលេខ ១១២១ ឧរថ.សក.ប្រក ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ស្ដីពី ការធ្វើប្រតិភូកម្មអំណាចជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល លើការចេញលិខិតអនុញ្ញាតឲ្យនាំចូលសារធាតុគីមី សម្រាប់បម្រើផលិតកម្មឧស្សាហកម្ម
- បានឃើញប្រកាសអន្តរក្រសួងលេខ ៣៧៩ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ ឧសភាឆ្នាំ ២០១១ ស្ដីពីការកំណត់កម្រៃសេវាកម្មចំពោះការផ្ដល់វិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ អាជ្ញាប័ណ្ណចុះបញ្ជី ផលិតផល និងលិខិតបញ្ជាក់មុខសញ្ញា និង/ឬស្ដងដារប្រើប្រាស់សារធាតុគីមីក្នុងវិស័យឧស្សាហកម្ម
- ប្រកាសលេខ ៦៧០ ឧរថ.បល.ប្រក ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០១១ ស្ដីពីការធ្វើប្រតិភូកម្មការងារគ្រប់គ្រងសារធាតុគីមី និងការចុះបញ្ជីផលិតផល
- ពិនិត្យសំណូមពរចាំបាច់របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

សម្រេច

ប្រការ ១: ប្រកាសនេះមានគោលបំណងពង្រឹងប្រសិទ្ធភាពនៃការត្រួតពិនិត្យ ការប្រើប្រាស់សារធាតុគីមីដែលជាវត្ថុធាតុដើមមួយសំខាន់បំរើផលិតកម្មក្នុងវិស័យឧស្សាហកម្ម និងសំដៅសំរួលធុរកិច្ចរបស់វិស័យឯកជន ក្នុងការផ្គត់ផ្គង់ ការចែកចាយ និងការប្រើប្រាស់សារធាតុគីមីតាមមុខសញ្ញាស្របច្បាប់របស់ខ្លួន ។

ប្រការ ២: ធុរជនសំដៅទៅលើនីតិបុគ្គលឬរូបវន្តបុគ្គលដែលស្នើសុំបញ្ជាក់មុខសញ្ញា និងបរិមាណប្រើប្រាស់សារធាតុគីមី ក្នុងគោលបំណងប្រើប្រាស់ក្នុងរោងចក្រ សិប្បកម្ម ឬលក់ចែកចាយបន្ត ។

ប្រការ ៣: រាល់ការស្នើសុំលិខិតបញ្ជាក់មុខសញ្ញា និងបរិមាណប្រើប្រាស់សារធាតុគីមី ក្នុងគោលបំណងផ្សេងៗ លើកលែងតែក្នុងគោលបំណងយកមកប្រើប្រាស់សំរាប់ផលិតឱសថ ត្រូវបំពេញពាក្យ និងបែបបទស្នើសុំនៅលេខាធិការដ្ឋានច្រកចេញ-ចូលតែមួយ នៃអគ្គនាយកដ្ឋានឧស្សាហកម្ម ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រាល់ថ្ងៃធ្វើការពេលព្រឹកម៉ោង ៨.៣០-១១.០០ និងពេលល្ងាចពីម៉ោង ១៤.៣០-១៦.៣០ ។

ប្រការ ៤: សំណុំឯកសារស្នើសុំលិខិតបញ្ជាក់មុខសញ្ញា និងបរិមាណប្រើប្រាស់សារធាតុគីមី ត្រូវបំពេញឲ្យបានត្រឹមត្រូវគ្រប់លក្ខណៈស្របតាមគំរូដូចមានចែងក្នុងឧបសម្ព័ន្ធ១នៃប្រកាសនេះ។
ការទទួលពាក្យស្នើសុំ និងកម្រៃសេវានៅលេខាធិការដ្ឋានច្រកចេញ-ចូលតែមួយនៃអគ្គនាយក

ដ្ឋានឧស្សាហកម្ម ត្រូវមានចុះលេខសំគាល់ ឈ្មោះអ្នកស្នើសុំ គោលបំណង និងកាលបរិច្ឆេទទទួលពាក្យច្បាស់លាស់ក្នុងសៀវភៅឯកសារចូល និងចេញវិក័យបត្រទទួលពាក្យស្នើសុំដោយមានការចុះហត្ថលេខារបស់អ្នកស្នើសុំ ។

ប្រការ ៥: អាស្រ័យលើប្រវត្តិនៃការស្នើសុំ ឯកសារចាំបាច់សំខាន់ៗដែលត្រូវផ្តល់ជូនជាមួយពាក្យស្នើសុំ បញ្ជាក់មុខសញ្ញានិងបរិមាណប្រើប្រាស់សារធាតុគីមីមានដូចខាងក្រោម:

១- តារាងព័ត៌មានសុវត្ថិភាពសារធាតុគីមី Material Safety Data Sheet (MSDS)

២- វិញ្ញាបនបត្រវិភាគសារធាតុគីមី

៣- គំរូសារធាតុគីមីដែលស្នើសុំ

៤- ច្បាប់ថតចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់ធុរជន

៥- ច្បាប់ថតចំលងអាជ្ញាប័ណ្ណចុះបញ្ជីពាណិជ្ជកម្ម និងប័ណ្ណប៉ាតង់ ឬប្រកាសអនុញ្ញាតបង្កើតរោងចក្រ សិប្បកម្ម ឬលិខិតចុះបញ្ជីសិប្បកម្ម ឬវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ សិប្បកម្ម ដែលមានសុពលភាព។

៦- តារាងព័ត៌មានលំអិតនៃសារធាតុគីមីស្នើសុំ

៧- របាយការណ៍សង្ខេបនៃការប្រើប្រាស់សារធាតុគីមីកន្លងមក ដោយភ្ជាប់ជាមួយនូវឯកសារនាំចូល និងឯកសារប្រើប្រាស់

៨- គម្រោងផែនការសង្ខេបនៃការប្រើប្រាស់សារធាតុគីមីដែលស្នើសុំ

៩- សេចក្តីប្រកាសទទួលខុសត្រូវចំពោះមុខច្បាប់របស់អ្នកស្នើសុំ

១០- លិខិតផ្ទេរសិទ្ធិរបស់ធុរជនផ្តល់ជូនអ្នកតំណាង ដើម្បីទំនាក់ទំនង និងដំណើរការស្នើសុំ

តម្រូវការនៃឯកសារខាងលើនេះ ត្រូវផ្តល់ជូនតាមករណីដូចខាងក្រោម:

ក- សម្រាប់ធុរជនដែលស្នើសុំលើកដំបូង ត្រូវភ្ជាប់ជាមួយពាក្យស្នើសុំនូវឯកសារចែងក្នុងចំណុច១ ៤ ៥ ៦ ៨ ៩ និង១០។

ខ- ក្នុងករណីការស្នើសុំលើកទីពីរ និងបន្តបន្ទាប់ ត្រូវភ្ជាប់ជាមួយពាក្យស្នើសុំ នូវឯកសារចែងក្នុងចំណុច១ ៤ ៥ ៦ ៧ ៨ ៩ និង ១០ ។ ចំពោះឯកសារក្នុងចំណុចលេខ ៤ ត្រូវផ្តល់ជូនឡើងវិញ ក្នុងករណីមានការកែប្រែអត្តសញ្ញាណរបស់ធុរជន ។ ចំពោះឯកសារក្នុងចំណុចលេខ ៥ ត្រូវផ្តល់ជូនឡើងវិញ ក្នុងករណីឯកសារមុនអស់សុពលភាព ឬមានការកែប្រែ ។

គ- ក្នុងករណីការស្នើសុំលើកទីពីរ និងបន្តបន្ទាប់ ប៉ុន្តែបរិមាណមានការប្រែប្រួលខ្លាំងខុសពីលើកមុន ឬប្រែប្រួលប្រភេទសារធាតុគីមី ធុរជនចាំបាច់ត្រូវផ្តល់លិខិតអំណះអំណាងបន្ថែមអំពីហេតុផលនៃការប្រែប្រួលនេះ។

ឃ- ក្នុងករណីសារធាតុគីមីដែលពុំធ្លាប់នាំចូល ឬប្រើប្រាស់ពីមុននៅក្នុងព្រះរាជាណាចក្រកម្ពុជាធុរជនចាំបាច់ត្រូវភ្ជាប់នូវឯកសារបន្ថែមដូចមានក្នុងចំណុច ២ និង ៣ ព្រមជាមួយ

លិខិតអំណះអំណាងហេតុផលនៃតម្រូវការប្រើប្រាស់សារធាតុគីមីនេះ ។

ខ- រាល់ឯកសារភ្ជាប់ដូចបានរៀបរាប់ខាងលើ ត្រូវមានប្រថាប់ត្រាក្រុមហ៊ុន ។

ប្រការ ៦: ធុរជនត្រូវបំពេញឈ្មោះសារធាតុគីមីនៅក្នុងពាក្យសុំដោយអនុលោមទៅតាម:

- ឈ្មោះសារធាតុគីមីប្រើប្រាស់តាមប្រព័ន្ធអន្តរជាតិ (IUPAC- International Union of Pure and Applied Chemistry) ឬឈ្មោះសារធាតុគីមីប្រើប្រាស់ក្នុងគោលបំណងពាណិជ្ជកម្ម (Trade/ Commercial Name) ឬឈ្មោះសារធាតុគីមីដែលប្រើប្រាស់តាមទីផ្សារ ឬតាមទំលាប់ធម្មតា (Common Name) ឬប្រព័ន្ធលេខកូដរបស់សារធាតុគីមី (CAS.N°- Chemical Abstract Service Number /CAS Registry Number)
- ឈ្មោះប្រទេសនាំចូលមកកម្ពុជា
- មុខសញ្ញា និងបរិមាណប្រើប្រាស់

ប្រការ ៧: ធុរជនដែលស្នើសុំលិខិតបញ្ជាក់មុខសញ្ញា និងបរិមាណប្រើប្រាស់សារធាតុគីមី នៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលនឹងត្រូវបានធ្វើការចុះបញ្ជីប្រើប្រាស់សារធាតុគីមីដោយស្វ័យប្រវត្តិ។ ធុរជនត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំរាល់ព័ត៌មានផ្សេងៗទាក់ទងការប្រើប្រាស់សារធាតុគីមី ក្នុងករណីមានការប្រែប្រួល។

ប្រការ ៨: ធុរជននឹងត្រូវទទួលបានការឆ្លើយតបលើលិខិតបញ្ជាក់មុខសញ្ញា និងបរិមាណប្រើប្រាស់សារធាតុគីមី ៖

- ក្នុងរយះពេល ៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ ចំពោះសារធាតុគីមីធ្លាប់ប្រើប្រាស់ឬនាំចូលកន្លងមកដោយធុរជន
- ក្នុងរយះពេល ១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ ចំពោះសារធាតុគីមីថ្មីមិនធ្លាប់ប្រើប្រាស់ ឬមិនធ្លាប់នាំចូលកន្លងមកដោយធុរជន
- ក្នុងរយះពេល ៦០(ហុកសិប)ថ្ងៃ នៃថ្ងៃធ្វើការ ចំពោះសារធាតុគីមីថ្មីដែលមិនធ្លាប់មានប្រើប្រាស់ ឬនាំចូលមកកម្ពុជាកន្លងមក
- ក្នុងករណីដែលលិខិតបញ្ជាក់មុខសញ្ញា និងបរិមាណប្រើប្រាស់សារធាតុគីមី ត្រូវបានបដិសេធ ធុរជននឹងត្រូវបានផ្តល់នូវព័ត៌មាន និងមូលហេតុច្បាស់លាស់អំពីការបដិសេធនេះជាលាយល័ក្ខអក្សរ ។

ប្រការ ៩: ធុរជនដែលទទួលបានលិខិតបញ្ជាក់មុខសញ្ញា និងបរិមាណប្រើប្រាស់សារធាតុគីមី ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវធ្វើរបាយការណ៍លំអិតអំពីការចរាចរ និងការប្រើប្រាស់សារធាតុគីមីដែលកំណត់ក្នុងលិខិតបញ្ជាក់ ជារៀងរាល់ខែ មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។ ក្នុងករណីខកខានមិនបានផ្តល់របាយការណ៍នេះ នឹងត្រូវទទួលការពិន័យស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

p

ប្រការ ១០: ធុរជនត្រូវជូនដំណឹងជាមុនក្នុងរយៈពេល ១៥ ថ្ងៃ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អំពីការនាំចូលមកដល់នៃសារធាតុគីមីដែលបានស្នើសុំ ដើម្បីក្រសួងចាត់មន្ត្រីមានសមត្ថកិច្ចចុះធ្វើការពិនិត្យលើអត្តសញ្ញាណ បរិមាណ និងសុវត្ថិភាពនៃការទុកដាក់សារធាតុគីមីដែលបានស្នើសុំ មុនពេលបញ្ចូលឃ្លាំង តាមការចាំបាច់ ។

ប្រការ ១១: រៀងរាល់ការនាំចូលនីមួយៗធុរជនត្រូវផ្តល់ជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នូវច្បាប់ចម្លងវិញ្ញាបនបត្រវិភាគសារធាតុគីមីដែលបាននាំចូលជាក់ស្តែងក្នុងរយៈពេលយ៉ាងយូរ ១៥ ថ្ងៃ បន្ទាប់ពីការនាំចូល ។

ប្រការ ១២: ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អាចចាត់មន្ត្រីចុះធ្វើអធិការកិច្ច ត្រួតពិនិត្យវាយតម្លៃលើការគ្រប់គ្រង ការស្តុកទុក និងការប្រើប្រាស់សារធាតុគីមីតាមការចាំបាច់ ដោយក្រសួងទទួលបន្ទុករាល់ការចំណាយលើការចុះត្រួតពិនិត្យនេះ ។ ការរារាំងណាមួយដល់ដំណើរការចុះត្រួតពិនិត្យរបស់មន្ត្រីមានសមត្ថកិច្ចរបស់ក្រសួង ដែលបង្កឡើងដោយធុរជន ឬបុគ្គលរបស់ធុរជននឹងត្រូវទទួលទោសពិន័យស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ប្រការ ១៣: ធុរជនដែលស្នើសុំបញ្ជាក់មុខសញ្ញា និងបរិមាណប្រើប្រាស់សារធាតុគីមីដើម្បីយកទៅចែកចាយបន្តត្រូវ ៖

- មានការកត់ត្រាឈ្មោះ មុខរបរ អាស័យដ្ឋាន អ្នកត្រូវទទួលបន្ត
- មានការកត់ត្រាឈ្មោះសារធាតុគីមី មុខសញ្ញាប្រើប្រាស់ និងបរិមាណសារធាតុគីមីចែកចាយបន្ត
- ត្រូវមានស្លាកសញ្ញានៅលើសំបកវេចខ្ចប់ និងភ្ជាប់តារាងព័ត៌មានសុវត្ថិភាពសារធាតុគីមី (MSDS) ដោយសរសេរអក្សរជាភាសាខ្មែរ ។

ប្រការ ១៤: ធុរជនត្រូវរក្សាគ្រប់ឯកសារ សក្ខីប័ត្រ វិក័យប័ត្រ និងឯកសារពាក់ព័ន្ធផ្សេងៗទៀត ក្នុងការនាំចូល ចរាចរ និងប្រើប្រាស់សារធាតុគីមីទាំងអស់ យ៉ាងតិចក្នុងរយៈពេល ០២ (ពីរ) ឆ្នាំ ក្រោយប្រតិបត្តិការទាំងនោះបានកើតឡើង ។

ប្រការ១៥: ធុរជនត្រូវ៖

- មានអ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រងសារធាតុគីមី
- ទុកដាក់សារធាតុគីមីឲ្យបានសមស្របតាមលក្ខណៈបច្ចេកទេស និងធានាថាឃ្លាំងមានសុវត្ថិភាព
- រៀបចំឲ្យមានការបណ្តុះបណ្តាលដល់កម្មករ អំពីសុវត្ថិភាពទុកដាក់ និងប្រើប្រាស់សារធាតុគីមី
- ផ្តល់នូវសម្ភារៈឧបករណ៍សុវត្ថិភាពការពារដល់កម្មករ
- មានស្លាកសញ្ញាសុវត្ថិភាព និងឧបករណ៍ ឬប្រព័ន្ធការពារអគ្គិភ័យ
- មានឧបករណ៍ សំភារៈ សំរាប់ផ្ទុកសារធាតុគីមីដែលធានាបាននូវសុវត្ថិភាពមិនជ្រាប ហៀរ

p

កំពប់ ធ្លាយ ហើរ ភាយ ច្រេះ ស៊ីកាត់ ។ល។ ក្នុងការដឹកជញ្ជូន លើកដាក់សារធាតុគីមី

- មានវិធានការគ្រប់គ្រងសំណល់សារធាតុគីមី ដោយអនុលោមទៅតាមច្បាប់ និងបទដ្ឋានបច្ចេកទេសដែលមានជាធរមាន ។

ប្រការ ១៦: ប្រកាស និងសេចក្តីសំរេចទាំងឡាយណាដែលមានន័យផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ១៧: អគ្គនាយកដ្ឋានឧស្សាហកម្ម នាយកដ្ឋាន អង្គភាពចំណុះអគ្គនាយកដ្ឋានឧស្សាហកម្ម លេខាធិការដ្ឋានច្រកចេញ-ចូលតែមួយនៃអគ្គនាយកដ្ឋានឧស្សាហកម្ម មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានី-ខេត្ត និងធុរជន មានភារកិច្ចអនុវត្តក្នុងក្របខណ្ឌសមត្ថកិច្ចរៀងៗខ្លួនតាមប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

<u>កន្លែងទទួល:</u>

- រាជកិច្ច
- ទីស្តីការគណៈរដ្ឋមន្ត្រី
  ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- ក្រសួងសុខាភិបាល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- សភាពាណិជ្ជកម្មកម្ពុជា
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា
  សម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា
  " ដើម្បីជូនជ្រាប និងផ្សព្វផ្សាយ "
- ដូចប្រការ ១៧ " ដើម្បីអនុវត្តន៍ "
  ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធ១

គោរពជូន

ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ពាក្យស្នើសុំ
លិខិតបញ្ជាក់មុខសញ្ញា និងបរិមាណ
ប្រើប្រាស់សារធាតុគីមី

រោងចក្រ សិប្បកម្ម ក្រុមហ៊ុន :..

....

សំរាប់មន្ត្រីជំនាញ:

លេខចុះបញ្ជីការ : ....

ថ្ងៃទី ខែ ឆ្នាំ ២០...

ពាក្យសុំលិខិតបញ្ជាក់មុខសញ្ញាប្រើប្រាស់សារធាតុគីមី

APPLICATION FORM FOR CHEMICAL SUBSTANCE LICENSE

ឈ្មោះអ្នកស្នើសុំ : ______ សញ្ជាតិ: ______ ភេទ: ☐ ប្រុស(Male)

Applicant's Name ______ Nationality ______ Sex ☐ ស្រី(Female)

លេខអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន (ID/Passport Number) *: ______ អាយុ(Age): ______

អាស័យដ្ឋានអ្នកស្នើសុំ(Applicant's address) * : ______

______

លេខទូរស័ព្ទទំនាក់ទំនង(Telephone Number): ______ លេខទូរសារ(Fax Number): ______

លេខចុះបញ្ជីការ អ្នកសុំបញ្ជាក់មុខសញ្ញាប្រើប្រាស់សារធាតុគីមី(Applicant Chemical Substance Registration No.): ______

☐ ស្នើសុំចុះបញ្ជីថ្មី-សំរាប់អ្នកស្នើសុំថ្មីដែលពុំទាន់បានចុះបញ្ជី(Request for New Registration - for New Applicant)

បំពេញព័ត៌មានខាងក្រោមប្រសិនបើអ្នកស្នើសុំជានិតិបុគ្គលហើយដែលពុំទាន់ចុះបញ្ជី ឬចុះបញ្ជីរួចហើយប៉ុន្តែសុំកែប្រែព័ត៌មានឡើងវិញ

(Fill in the following form if you are a new applicant or wish to update current registration information)

តួនាទី និងមុខងាររបស់អ្នកស្នើសុំក្នុងក្រុមហ៊ុន : ☐ ប្រធានក្រុមហ៊ុន (Chairman/Managing Director/Director)

Position of applicant in company/firm ☐ ដៃគូ ឬតំណាងស្របច្បាប់របស់ក្រុមហ៊ុន(Partner or duly representative)

យោងលិខិតបង្គាប់តែងតាំងជាតំណាង(Authorized Letter of Company Representative) *: ______

______

នាមករណ៍ក្រុមហ៊ុន : ______ លេខចុះបញ្ជីពាណិជ្ជកម្ម *(Business Registration Number):

Firm/Company's Name : ______ ______(បើមាន)

អាស័យដ្ឋានស្នាក់ការអចិន្ត្រៃយ៍(Permanent address) : ______

______

លេខទូរស័ព្ទទំនាក់ទំនង(Telephone Number): ______ លេខទូរសារ(Fax Number): ______

ប្រភេទសកម្មភាពជំនួញរបស់ក្រុមហ៊ុន-សិប្បកម្ម(Nature of Business) ______

លិខិតអនុញ្ញាតផលិតកម្ម-អាជីវកម្មពាក់ព័ន្ធ(Related License) ______

គោលបំណងនៃការស្នើសុំ(Purpose of Chemical Substance):

☐ នាំចូលដើម្បីប្រើប្រាស់ផ្ទាល់ខ្លួន(Import for Personal Use)

☐ នាំចូលដើម្បីលក់បន្តក្នុងស្រុក(Import for Local Sale)

☐ នាំចូលដើម្បីប្រើប្រាស់ក្នុងផលិតកម្ម-សិប្បកម្មផ្ទាល់ខ្លួន (Import for Production/Manufacture)

☐ ទិញក្នុងស្រុកដើម្បីធ្វើការនាំចេញ ឬលក់បន្តក្នុងស្រុក (Purchase for Local Export or Sale)

☐ នាំចូលដើម្បីធ្វើការនាំចេញ(Import for Export)

☐ គោលបំណងផ្សេងក្រៅពីនេះ(Others): ______

សំណើសុំរយៈពេលសុពលភាពនៃលិខិតបញ្ជាក់(Period of License/Permit Requested): ______ ខែ(Month(s))

ឯកសារភ្ជាប់ជាមួយ (Documents to be Attached) :

១-តារាងព័ត៌មានសុវត្ថិភាពសារធាតុគីមី (Material Safety Data Sheet)

២-វិញ្ញាបនប័ត្រវិភាគសារធាតុគីមី (Test Certificate of Requested Chemical Substance)

៣-គំរូសារធាតុគីមីដែលស្នើសុំ (Sample of Requested Chemical Substance)

៤-ច្បាប់ថតចំលងអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែនរបស់ជុជន (Copy of ID or Passport)

p

៥-ច្បាប់ថតចម្លងអាជ្ញាប័ណ្ណចុះបញ្ជីពាណិជ្ជកម្មនិងប៉ាតង់ ឬប្រកាសអនុញ្ញាតបង្កើតរោងចក្រ សិប្បកម្ម ឬលិខិតចុះបញ្ជីសិប្បកម្ម ឬវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ សិប្បកម្មដែលមានសុពលភាព។ (Copy of Valid Business Registrat.on Certificate and Patent or Factory/Manufacture Perm.t, or Registered Manufacture Certificate or Permit Certificate for Factory/Manufacture)

៦-តារាងព័ត៌មានលំអិតនៃសារធាតុគីមីស្នើសុំ (Chemical Substance Application Details)

៧-របាយការណ៍សង្ខេបនៃការប្រើប្រាស់សារធាតុគីមីកន្លងមក ដោយភ្ជាប់មកជាមួយនូវឯកសារនាំចូល និងឯកសារប្រើប្រាស់ (Summary of Monthly Report of Previous Chemical Substance Transaction)

